# សិលាចារឹកប្រាសាទព្រៃក្មេង K.៧៧៤

## ១- ព័ត៌មានទូទៅ

ប្រាសាទព្រៃក្មេងមានទីតាំងនៅភូមិបឹងខ្នារ ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប នៅទិសនីរតីនៃបារាយណ៍ទឹកថ្លា(បារាយណ៍ខាងលិច)។ ប្រាសាទនេះ មានឈ្មោះល្បីល្បាញដោយសារផ្តែរនិងសសរពេជ្រប្រាសាទនេះ ត្រូវអ្នកប្រវត្តិសិល្បៈកំណត់យកជាគោលនិងជាឈ្មោះរចនាបថមួយ នៅសម័យមុនអង្គរ រវាងពាក់កណ្ដាលទី២ស.វ.ទី៧ គឺរចនាបថព្រៃក្មេង។ នៅប្រាសាទព្រៃក្មេង ក៏មានសិលាចារឹកចារនៅមេទ្វារមួយផ្ទាំង ចុះលេខសម្គាល់ K.៧៧៤ ដែលរកឃើញជាមួយនឹងផ្តែរនិងសសរពេជ្រ ដោយបុរាណវិទូបារាំងនាឆ្នាំ១៩៣៣។ សិលាចារឹកនេះចារលើថ្មភក់ មានចំណារខ្លះមិនសូវច្បាស់ល្អ នាំឱ្យមានបញ្ហាចោទលើអំណានមួយចំនួន ជាពិសេស គឺអំណានកាលបរិច្ឆេទ។ អត្ថបទចារជាភាសាខ្មែរបុរាណសរុបមានចំនួន១៣បន្ទាត់ មានចុះកាលបរិច្ឆេទ៣ដង ដែលសុទ្ធសឹងតែស្ថិតនៅសម័យអង្គរ។ កាលបរិច្ឆេទទីមួយ នៅមហាសករាជឆ្នាំ៧៨២ (គ.ស.៨៦០) ទីពីរនៅមហាសករាជឆ្នាំ៩១៧ (គ.ស.៩៩៥) និងចុងក្រោយនៅមហាសករាជឆ្នាំ៩១១ (គ.ស.៩៨៩)។ លោកហ្វីលីព ចឺណ្ណោរ បានបង្ហាញថាលោក ក្លូដ ហ្សាក់ បានអានសិលាចារឹកជាថ្មី និងស្នើកាលបរិច្ឆេទនៅបន្ទាត់ទី១ ថាជាមហាសករាជឆ្នាំ៨៦០ (គ.ស.៩៣៨) និងកាលបរិច្ឆេទនៅបន្ទាត់ទី៨ ដែលលោក សឺដេស អានជា ៨១៧ ថាជាមហាសករាជឆ្នាំ៩១៧ (គ.ស. ៩៩៥) វិញ។ យើងពុំទាន់អាចរកឃើញឯកសារអំណានរបស់លោក ក្លូដ ហ្សាក់ ដើម្បីពិនិត្យបញ្ជាក់នៅឡើយ។

ប្រាសាទព្រៃក្មេងកសាងឡើងនៅសម័យចេនឡា នាសតវត្សទី៧ ដោយព្រះបាទស្រីជ័យវម៌្មទី១ ដើម្បីឧទ្ទិសដល់ព្រះឥសូរ។ ប្រាសាទនេះ សាងសង់ដោយប្រើឥដ្ឋ ថ្មបាយក្រៀម និងថ្មភក់ នៅលើទីទួល បែរមុខទៅទិសខាងកើត និងមានស្នាមភ្លោះព័ទ្ធជុំវិញ។ បុរាណវិទូបារាំងមកដល់ទីនេះជាលើកដំបូងនៅឆ្នាំ១៩៣៣ បានរកឃើញផ្តែរ សសរពេជ្រ និងសិលាចារឹកមួយផ្ទាំង។ ផ្តែរនិងសសរពេជ្រប្រាសាទព្រៃក្មេង ត្រូវគេយកទៅរក្សា

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ទុកនៅសារមន្ទីរហ្គីមេត៍ ប្រទេសបារាំង។ ចំណែកសិលាចារឹកដែលរកឃើញចុះលេខសម្គាល់ K.៧៧៨ បច្ចុប្បន្នរក្សាទុកដោយអាជ្ញាធរជាតិអប្សរា។ តាមការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញ តំបន់នេះ គឺជាទីតាំងរស់នៅរបស់សហគមន៍មនុស្សតាំងសម័យបុរេប្រវត្តិមកម៉្លេះ។ ក្រោយមក គឺនៅសម័យមុនអង្គរ មានការសង់ប្រាសាទឡើងទុកទីសក្ការៈបូជា និងបន្តរហូតមកដល់សតវត្សទី៩រហូតដល់ទី១០ ក៏នៅមានមនុស្សបន្តទៅធ្វើបុណ្យនៅទីនោះដដែល។

## ២- ប្រវត្តិនៃការសិក្សាសិលាចារឹក

សិលាចារឹក K.៧៧៨ នេះ ធ្លាប់បានសិក្សារួចមកហើយ ដោយលោកសាស្ត្រាចារ្យ ហ្ស៊ក សឺដេស ចុះផ្សាយនៅឆ្នាំ១៩៥២ ក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៤។[១] បន្ទាប់មកលោកសាស្ត្រាចារ្យ ហ្វីលីព ចេណ្ណឺរ បានលើកយកមកសិក្សាដែរក្នុង Part xml, № 97 និងចេញផ្សាយលើគេហទំព័រ http://sealang.net/ok/corpus.htm។

ចំពោះបញ្ហាចោទលើអំណានកាលបរិច្ឆេទ តាមរយៈការផ្ទៀតផ្ទាត់ នៅបន្ទាត់ទី១ យើងយល់ស្របទៅតាមអំណានរបស់លោក សឺដេស ប៉ុន្តែយើងក៏យល់ស្របតាមគំនិតរបស់លោក ក្លូដ ហ្សាក់ ដែលបានស្នើកាលបរិច្ឆេទនៅបន្ទាត់ទី៨ មកជាឆ្នាំ៩១៧ វិញ។ តាមរយៈតួលេខបានបង្ហាញឱ្យឃើញច្បាស់ថា តួលេខទី១ គឺជាលេខ «៩» ពុំមែនជាលេខ «៨» ដូចការអានរបស់លោក ហ្ស៊ក សឺដេស នោះទេ។ ការដែលលោក សឺដេស អានជាមហាសករាជឆ្នាំ «៨១៧» ដោយសារលោកទាញយកសាច់រឿងនៅខាងមុខ ត្រង់កាលដែលឆ្លងប្រាសាទភ្នំបាខែង មកភ្ជាប់ឱ្យស្របគ្នា។ ប៉ុន្តែយើងយល់ថាសេចក្តីដែលគេរៀបរាប់អំពីព្រះបាទស្រីយសោវម៌្មទេវទី១ ស្តេចប្រទានតង្វាយផ្សេងៗចំពោះប្រាសាទនេះ គឺដើម្បីជាសេចក្តីបង្ហាញដល់សាច់រឿងនាមហាសករាជឆ្នាំ៩១១/២ មានវិវាទទាមទារកាន់កាប់ទ្រព្យសម្បត្តិនោះកើតឡើយ ប៉ុន្តែពុំបានសម្រេចទេ គឺត្រូវប្រគល់ទ្រព្យសម្បត្តិទៅដល់

[១] Cœdès,1952.

ប្រាសាទនេះវិញប៉ុណ្ណោះ។ រឿងសំខាន់ គឺនៅមហាសករាជឆ្នាំ៩១៧ ក្រុមការងារស៊ើបអង្កេតរបស់ព្រះសភា ចុះមកកំណត់សិទ្ធិកាន់កាប់ថានរណាជាអ្នកមានទ្រព្យទាំងនោះ។ ដោយសារអត្ថបទសិលាចារឹកនេះ ចារសេចក្ដីរៀបរាប់ខ្លីៗ ពុំរៀបរាប់រឿងវែងអន្លាយហូរហែដូចសិលាចារឹកវែងៗទាក់ទងនឹងបញ្ហាដីធ្លី ទើបយើងអាចពិបាកឬយល់សេចក្ដីពុំសូវច្បាស់។ សូមអានសេចក្ដីបកប្រែដែលយើងស្នើជាថ្មី ដើម្បីយល់ពីសេចក្ដីនៃសិលាចារឹកនេះ។

## ៣- អត្ថន័យសង្ខេប

កម្មវត្ថុសំខាន់នៃសិលាចារឹកនេះ បង្ហាញពីសិទ្ធិគ្រប់គ្រងដីធ្លី ខ្ញុំបម្រើ និងទ្រព្យសម្បត្តិរបស់ប្រាសាទព្រះគម្តែងអញស្រីអារ្យា។ រឿងដែលសំខាន់ គេចារនៅត្រង់ពាក់កណ្ដាលនៃអត្ថបទ ដែលបង្ហាញថានៅក្នុងមហាសករាជឆ្នាំ៩១៧ (គ.ស.៩៩៥) គឺក្នុងរាជ្យព្រះបាទស្រីជ័យវម៌្មទេវទី៥ ក្រុមអ្នកស៊ើបអង្កេតរបស់ព្រះសភា(តុលាការ) ចុះមកកំណត់សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្រាសាទនេះ។

នៅផ្នែកដំបូងនៃសិលាចារឹក បានរៀបរាប់រំឭកទៅដល់មហាសករាជឆ្នាំ៧៨២ (ត្រូវនឹងគ្រិស្តសករាជ៨៦០) ដែលកាលនោះ ព្រះបាទស្រីជ័យវម៌្មទេវទី៣ បានថ្វាយតង្វាយចំពោះព្រះមានគ្រែស្នេង និងដីធ្លី។ នៅរាជ្យនោះដែរ តេងហ្យង ដែលជាអ្នកប្រចាំការបម្រើព្រះបានថ្វាយនូវភាជន៍ អ្នកបម្រើ២នាក់ ថ្មបស១។ ព្រះមហាក្សត្របានប្រទានអ្នកបម្រើនិងស្រុកមួយដល់តេងហ្យង។ បើផ្អែកទៅតាមសិលាចារឹកប្រាសាទគោកចក យើងអាចដឹងថា តេងហ្យង គឺជាសាច់ថ្លៃរបស់ព្រះបាទស្រីជ័យវម៌្មទេវទី៣ ដែលទទួលភារៈជំនួសព្រះអង្គ ដើម្បីប្រើនិងចាត់ចែងអ្នកបម្រើដើម្បីបម្រើព្រះគម្តែងអញសកព្រាហ្មណ៍នៅវិស្ណុគ្រាម[២]។

ផ្នែកទី២ បានបង្ហាញថា នៅមហាសករាជឆ្នាំ៩១៧ (ត្រូវនឹងគ្រិស្តសករាជ៩៩៥) ក្រុមអ្នកស៊ើបក្ដីរបស់សភា (តុលាការ) បានកំណត់ថាពុំអាចមាននរណាជាម្ចាស់សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិនិងខ្ញុំបម្រើនៅប្រាសាទព្រះគម្តែងអញស្រីអារ្យា ក្រៅពីវាបប្រាណដែល

[២] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/25517

ជាអ្នកបានទិញជួរនោះឡើយ។ សេចក្ដីក៏រំឭកទៅដល់រាជ្យរបស់ព្រះបាទស្រីយសោវម៌្មទេវទី១ កាលដែលធ្វើបុណ្យឆ្លងប្រាសាទភ្នំបាខែង ទ្រង់ក៏បានថ្វាយតង្វាយមានខ្ញុំបម្រើស្រែ កុដិ ចំពោះប្រាសាទនេះ។ លុះមកដល់មហាសករាជឆ្នាំ៩១១/២ មានជម្លោះទាមទារសិទ្ធិកាន់កាប់ទ្រព្យទាំងនោះ ប៉ុន្តែពុំបានសម្រេចទេ គឺត្រូវប្រគល់សិទ្ធិកាន់កាប់ទៅប្រាសាទវិញ។ ដោយសារមានបញ្ហានេះហើយ ទើបនៅមហាសករាជឆ្នាំ៩១៧ ក្រុមអ្នកស៊ើបក្ដីចុះមកកំណត់សិទ្ធិកាន់កាប់នេះ។

## ៤- អត្ថបទសិលាចារឹកជាអក្សរខ្មែរទំនើប

១- ៧៨២គកនុវ្រះបាទស្ដាចិ[៣]ទៅវិម្នុលោកមោកិជូន្នគិរិកា•ប្រសាទភូមិវ្នំ{២}

២- នុស្រុកិ(ស្រែសំរេងិ[៤])ដេងិប្ទូនបត្និមធ្មិងក្រលាទុកបត្និមស្រុកិសប្តាហ

៣- ប្រសបិភូមិវ្រះកម្រតេងអញឥន្ទ្រានិតគិរាជ្យនោះឱក្កនុតេង

៤- ហ្យង(លា?)-វនបំចាំជូនភាជនម្វាយិខ្ញុំវ្យរថ្មោបិបសម្វាយស្រែផ្ទែគិ

៥- តោយិបុវ្វទោវតោយទក្សិណទោតោយិបត្និមទាល្ក

៦- ស្រុកិកលាទាត្ថ៌តោយិឧត្តរទាល្កស្រែវ្រះឥន្ទ្រានិ

៧- អ្នកិស្ញិកិ២តបង្គប្បំវេផ្សម្និស្រុកក្សុរណ្នំបុរឱយ្គតេងិហ្យង

៨- ៩១៧គកតគិបិរោចដេម្ហអង្គារវារិគិនុមានចារេវ្រះសភាវំអាចិតិ

៩- អ្នក្គមាន(ផោង)មានខ្ញុំនេះវ្រះកម្រតេងអញគ្រីអាយ៌្យាគិនាក្គមានវាបិ

១០- ប្រាណទគាធិក្ត្យទ្វារប(ា)លទុញ៊(ត្វរ?)ផោង្វតគិវ្រះរាជ្យស្ដាចិទៅបរមគិរលោកឆ្មោងិ

១១- វ្នំកន្ដាលនោះគិនុជូនខ្ញុំនេះដ្មោះតៃកន្ទាងិនុស្រែប្ទូនកុតិយិទុកិខ្ញុំនេះ

១២- ឱយតវ្រះកម្រតេងអញ•៩១១/២គកមានឧបវាទ(វ្នំ)សិ

១៣- ទ្និវិងតវ្រះកម្រតេងអញ

[៣] នៅខាងលើពាក្យនេះ មានជួសពាក្យ «៦ទិន» មានន័យថា «៦ថ្ងៃ» ដែលពុំពាក់ព័ន្ធនឹងឃ្លានេះឡើយ។

[៤] ពាក្យ «សំរេងិ» ជាស្ថាននាម មាននៅក្នុងសិលាចារឹកព្រះឥន្ទ្រកោសិយ K.២៦២ ដែរ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## ៥- អត្ថបទប្រែសម្រួល

(១-៧) មហាសករាជឆ្នាំ៧៨២ នូវព្រះបាទស្ដេចយាងទៅវិស្ណុលោក (ព្រះបាទស្រីជ័យវម៌្មទេវទី៣)(យាង)មកថ្វាយព្រះសិរិកា(គ្រែស្នែង) ថ្វាយដី ភ្នំ... និងស្រុកស្រែសំរេង (ទំហំ)បួនជើង ខាងលិចស្ទឹងក្រឡាទុក ខាងលិចស្រុកសប្ដាហ៍ ប្រសព្វដីព្រះគម្ដែងអញ ឥន្ទ្រានិ។ គឺនៅក្នុងរាជ្យនោះដែរ តេងហ្សង(លា?)-វនដែលជាអ្នកប្រចាំការ(បម្រើព្រះ) ថ្វាយភាជន៍១ អ្នកបម្រើ២នាក់ ថ្មបស[៥]១។ ស្រែជាបុណ្យនោះ គឺទិសខាងកើតរហូតទៅ ទិសខាងត្បូងរហូតទៅ ទិសខាងលិចទៅទល់នឹងស្រុកកលាទារត្រី ទិសខាងជើងទល់ស្រែ ព្រះឥន្ទ្រានិ។ អ្នកបម្រើ២ស៊ឹក (=៨០០នាក់) ដែលបង្គាប់(ឱ្យ)បម្រើផ្សំនឹងស្រុកសុវណ្ណបុរ (ព្រះបាទស្រីជ័យវម៌្មទេវទី២) ប្រទានដល់តេងហ្សង (ជាអ្នកអ្នកគ្រប់គ្រង)។

(៨-១០) មហាសករាជឆ្នាំ៩១៧ ៣រោជ ខែជេស្ឋ ថ្ងៃអង្គារ មានអ្នកស៊ើបក្ដីរបស់ព្រះសភា(តុលាការ) (កំណត់ថា)ពុំអាចមាននរណាជាម្ចាស់ទ្រព្យនិងខ្ញុំទាំងឡាយទាំងអស់នេះ (នៃ)ព្រះគម្ដែងអញស្រីអារ្យា(ឡើយ)។ អ្នកដែលមាន(សិទ្ធិ) គឺវាបប្រាណជាទសាធិក្ខត្យ[៦] ជាទ្វារបាល (បាន)ទិញជូរផង។

(១០-១៣) កាលក្នុងព្រះរាជ្យស្ដេចទៅបរមសិវលោក(ព្រះបាទស្រីយសោវម៌្មទេវទី១) (នៅពេលធ្វើពិធី)ឆ្លង(ប្រាសាទ)ភ្នំកណ្ដាល(ប្រាសាទភ្នំបាខែង)នោះ គឺ(ទ្រង់បាន)ថ្វាយអ្នកបម្រើឈ្មោះតែកន្ទាង ស្រែបួន កុដិ(ប្រាង្គប្រាសាទ) ទុកអ្នកបម្រើ(នៅទី)នេះថ្វាយចំពោះព្រះគម្ដែងអញ(ស្រីអារ្យា?)។ (ដល់)មហាសករាជឆ្នាំ៩១១/២ មានជម្លោះ (តែ)ពុំ(បាន)សិទ្ធិ(គ្រប់គ្រង) (ត្រូវប្រគល់)វិញដល់ព្រះគម្ដែងអញ៕

[៥] សូមអានបន្ថែម៖ https://www.yosothor.org/publications/khmer-renaissance/chapter-four/tmor-bos.html

[៦] ជាមន្ត្រីធំក្នុងចំណោមមន្ត្រីឬមនុស្សដប់នាក់។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

# ឯកសារពិគ្រោះ

Cœdès, G.

1952. Piédroit de Pràsàt Prei Kmeṅ (K. 774) in *Inscriptions du Cambodge*, Vol. 4. Paris.

Jenner, P.

Piédroit of Pràsàt Prei Kmeṅ in Part xml, № 97. http://sealang.net/ok/corpus.htm

O'reilly, D., Shewan, L., Domett, K. and Sopheap, A., 2020.

Revisiting Prei Khmeng: The excavation of an iron age settlement and cemetery in Cambodia. *Asian Perspectives*, *59*(1), pp.33-60.

## បញ្ជីរូបភាព



សំណៅផ្តិតសិលាចារឹកប្រាសាទព្រៃក្មេង (រូបថត៖ EFEO_ CAM17028-1)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



ប្រាសាទព្រៃក្មេងសព្វថ្ងៃ (រូបថត៖ https://helloangkor.com/attractions/prei-khmeng/)



ប្រាសាទព្រៃក្មេងសព្វថ្ងៃ (រូបថត៖ https://helloangkor.com/attractions/prei-khmeng/)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



ប្រាសាទព្រៃក្មេង (រូបថត៖ EFEO_ CAM08253)



ផ្ដែរនិងសសរពេជ្រប្រាសាទព្រៃក្មេង (រូបថត៖ EFEO_ CAM08094)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង